**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ**
លេខ:......០៤៩......អ.ក.វ.ក......................

ថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១

**សូមជម្រាបមក**

**ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងគោក**
**ឯកឧត្តម នាយឧត្តមនាវី អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងទឹក**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងអាកាស**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរង មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស**
**ឯកឧត្តម នាយក ស្ថាប័ន និងកងឯកភាពចំណុះក្រសួងការពារជាតិ**
**ឯកឧត្តម នាយក ស្ថាប័ន និងកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន**

**កម្មវត្ថុ** ស្តីពីដំណោះស្រាយការចាក់វ៉ាក់សាំងលើកទី២ ចំពោះយោធិន និងគ្រួសារដែលបានចាក់វ៉ាក់សាំងលើកទី១ នៅតាមកងឯកភាពជុំវិញរាជធានីភ្នំពេញ ក្នុងដំណាក់កាលអនុវត្តវិធានការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមគោលការណ៍របស់រាជរដ្ឋាភិបាល។

**យោង** សារាចរណែនាំលេខ ០០៦/២០២១ ស.ណ.ន ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងការពារជាតិ ស្តីពីវិធានការអនុវត្តសេចក្តីសម្រេច ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តម**ជ្រាបថា ដោយពិនិត្យឃើញថា កិច្ចដំណើរការចាក់វ៉ាក់សាំងជូនកងទ័ព និងគ្រួសារទូទាំងកងយោធពលខេមរភូមិន្ទ បាននឹងកំពុងប្រព្រឹត្តទៅក្នុងដំណាក់កាលចាក់លើកទី១ ជំហានទី២ នៅតាមបណ្តាស្ថាប័ន កងឯកភាពជុំវិញរាជធានីភ្នំពេញ និងនៅតាមបណ្តាគោលដៅក្នុងភូមិសាស្ត្រគ្រប់ខេត្ត។ ជាមួយគ្នានេះក៏មានគ្រួសារកងទ័ពមួយចំនួនបានមកបំពេញបែបបទ និងបានចាក់វ៉ាក់សាំងលើកទី១ ជាមួយគ្រួសារនៅតាមកងឯកភាពជុំវិញរាជធានីភ្នំពេញ ហើយបានវិលត្រឡប់ទៅទីស្នាក់អាស្រ័យរបស់ខ្លួនវិញនៅតាមខេត្តនានា ព្រមទាំងមិនអាចវិលត្រឡប់មកចាក់វ៉ាក់សាំងលើកទី២ នៅកន្លែងដើមវិញបាន ដោយស្ថិតក្នុងឱកាសដែលត្រូវអនុវត្តសេចក្តីសម្រេច ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមគោលការណ៍របស់រាជរដ្ឋាភិបាល។

អាស្រ័យហេតុនេះ អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ សូមណែនាំដល់គ្រប់ប្រភេទទ័ព ទ័ពជំនាញ បណ្តាយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករងខេត្ត កងរាជអាវុធហត្ថខេត្ត បណ្តាស្ថាប័ន កងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ដូចខាងក្រោម៖

១.ចាត់ចែងធ្វើការផ្សព្វផ្សាយជាការប្រញាប់ដល់យោធិន និងគ្រួសារដែលបានចាក់វ៉ាក់សាំងលើកទី១ (វ៉ាក់សាំងឈ្មោះ SINOPHARM) នៅតាមកងឯកភាពជុំវិញរាជធានីភ្នំពេញ ហើយមិនអាចធ្វើដំណើរពីបណ្តាខេត្តមកចាក់លើកទី២ នៅអង្គភាពដើមវិញបាន សូមទៅចុះឈ្មោះនៅតាមបណ្តាតំបន់ប្រតិបត្តិការសឹករងខេត្ត ឬទីបញ្ជាការយោធភូមិភាគ(ដោយភ្ជាប់ជាមួយនូវប័ណ្ណចាក់វ៉ាក់សាំងលើកទី១)។ តំបន់ប្រតិបត្តការសឹករងខេត្ត ត្រូវបូកសរុបរាយការណ៍ជូនយោធភូមិភាគ ហើយយោធភូមិភាគ ត្រូវសរុបរាយការណ៍ជូន អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ ដើម្បីពិនិត្យរៀបចំផ្គត់ផ្គង់វ៉ាក់សាំងជូនតាមសភាពការណ៍ជាក់ស្តែង។

២.ជាមួយគ្នានោះ បណ្តាយោធភូមិភាគ ត្រូវរៀបចំក្រុមការងារ ដើម្បីទទួលការចុះឈ្មោះ ការរៀបចំទីតាំង (នៅក្រៅជំរុំបន្ទាយ) ដែលមានលក្ខណៈស្របតាមវិធានណែនាំរបស់ក្រសួងសុខាភិបាល នៅយោធភូមិភាគ ឬនៅតំបន់ប្រតិបត្តិការសឹករងខេត្ត) និងក្រុមពេទ្យ ដើម្បីដំណើរការចាក់វ៉ាក់សាំងជូនយោធិន និងគ្រួសារដូចមានខាងលើ ដើម្បីចៀសវាងកុំឱ្យលើសពីការកំណត់បច្ចេកទេសវ៉ាក់សាំងដែលបានចាក់លើកទី១មកនោះ។

សេចក្តីដូចបានជម្រាបខាងលើ សូម**ឯកឧត្តម**ជ្រាបនិងចាត់វិធានការតាមការគួរ។

សូម**ឯកឧត្តម**ទទួលនូវការរាប់អានអំពីខ្ញុំ។

**រដ្ឋលេខាធិការប្រចាំការ ក្រសួងការពារជាតិ និងជាប្រធាន**
**អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ**

នាយឧត្តមសេនីយ៍.**នាង_ផាត**

**ចម្លងជូន៖**
- ឯកឧត្តម អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- ឯកឧត្តម អនុប្រធានអនុគណៈកម្មការចំពោះកិច្ច
- ឯកឧត្តម នាយខុទ្ទកាល័យ សម្តេចពិជ័យសេនា
- លេខាធិការដ្ឋាន អនុគណៈកម្មការចំពោះកិច្ច
  (ដើម្បីជូនជ្រាប)
- បណ្តាយោធភូមិភាគ និងតំបន់ប្រតិបត្តការសឹករងខេត្ត
- នាយកដ្ឋានបុគ្គលិក នាយកដ្ឋានសុខាភិបាល កពជ
- ទីចាត់ការបុគ្គលិក ទីចាត់ការសុខាភិបាល អគ្គបញ្ជាការ
  (ដើម្បីមុខការ)
- ឯកសារ- កាលប្បវត្តិ